# ព្រឹត្តិបត្រព័ត៌មាន

## គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច នៅតំបន់ទន្លេសាប(ធី.អេស.អេស.ឌី)

*ផ្តល់ថវិកាអនុវត្តដោយៈ ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម រដ្ឋាភិបាលហ្វាំងឡង់ និង រាជរដ្ឋាភិបាលកម្ពុជា*

គម្រោងទន្លេសាប ធី.អេស.អេស.ឌីៈ ជួយកែលម្អជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ប្រមាណជា ៦៣ម៉ឺនគ្រួសារ ក្នុង១៩៦ឃុំ ២៨ស្រុក ក្នុង ខេត្ត បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និង ត្បូងឃ្មុំ តាមរយៈ (១) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រដល់ផលិតភាពកសិកម្ម (២)ការបង្កើនសមត្ថភាពបច្ចេកទេសរបស់កសិករខ្នាតតូច (៣) ការផលិត-ផ្គត់ផ្គង់ពូជដំណាំមានគុណភាព និង (៤) ការផ្តល់ព័ត៌មានដល់កសិករ។

### មាតិកាសម្រាប់ត្រីមាសទី ១ ឆ្នាំ ២០១៦


១. និរន្តរភាពស្ថានីយ៍កសិកម្មបល្ល័ង្គ
២. កសិករចិញ្ចឹមជ្រូកនៅសណ្តាន់ទទួលជោគជ័យ
៣. ចំណូលបន្ថែមពីការចិញ្ចឹមកង្កែបសាច់អាចជួយជីវភាពបានប្រសើរ
៤. ការអភិវឌ្ឍន៍កសិកម្មខ្នាតតូចជួយកែលម្អជីវភាពគ្រួសារ


## ១ និរន្តរភាពស្ថានីយ៍កសិកម្មបល្ល័ង្គ



កំពង់ធំៈ ភូមិបល្ល័ង្គលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ស្ថិតនៅប្រហែល ១គីឡូម៉ែត្រពីទីរួមខេត្ត មានស្ថានីយ៍កសិកម្មបល្ល័ង្គ។ ស្ថានីយ៍កសិកម្មនេះ មានផ្ទៃដីសរុបទំហំ១៣ហិចតា ហើយដីនេះ មានលក្ខណៈអនុគ្រោះ សម្រាប់ដំណាំស្រូវរយៈពេលពេញមួយឆ្នាំ។ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូនៅតំបន់ទន្លេសាប ដែលត្រូវបានគាំទ្រហិរញ្ញវត្ថុដោយ ធនាគារអភិវឌ្ឍអាស៊ី មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម រដ្ឋាភិបាលហ្វាំងឡង់ និងរាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រស្ថានីយ៍កសិកម្មពីរកន្លែង ស្ថានីយ៍កសិកម្មបល្ល័ង្គក្នុងខេត្តកំពង់ធំ និងស្ថានីយ៍កសិកម្មទឹកវិលក្នុងខេត្តសៀមរាប ដែលស្ថានីយ៍នីមួយៗ ត្រូវបានគ្រប់គ្រងដោយមន្ទីរកសិកម្មខេត្ត។

ស្ថានីយ៍កសិកម្មបល្ល័ង្គ ត្រូវបានប្រគល់សិទ្ធិឲ្យធ្វើការសាកល្បងលើបច្ចេកវិទ្យាថ្មីៗ និងប្រភេទពូជ ដែលណែនាំឲ្យប្រើប្រាស់ដោយ CARDI មន្ទីរកសិកម្មខេត្ត ព្រមទាំងបច្ចេកវិទ្យានានាមកពីប្រភពផ្សេងទៀត។ តួនាទីមួយដ៏សំខាន់របស់ស្ថានីយ៍ គឺផលិតពូជសុទ្ធអនុញ្ញាតិដើម្បីលក់ចែកចាយដល់កសិករ និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីគាំទ្រឲ្យមានការកើនឡើងនូវផលិតភាពកសិកម្ម តាមរយៈការប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អ និងជួយសម្រួលដល់ការបញ្ចូលពូជ និងបច្ចេកវិទ្យាថ្មីៗ។

ស្ថានីយ៍កសិកម្មបល្ល័ង្គអាចដំណើរឡើងវិញដោយមានការជ្រោមជ្រែងពីគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ សាងសង់ឃ្លាំងមួយ ស្តារប្រឡាយ ធ្វើផ្លូវក្រាលគ្រួសក្រហមមួយខ្សែ



ចាក់គ្រឹះលានហាលសម្ងួត និងផ្ដល់ថវិការផលិតកម្ម។ ថ្មីៗនេះ ដើម្បីគាំទ្រដំណើរឱ្យកាន់តែប្រសើរគម្រោងក៏បានផ្ដល់ ត្រាក់ទ័រមួយគ្រឿង ឡសម្ងួត រថយន្តដឹកស្រូវមួយគ្រឿង ម៉ូតូមួយគ្រឿង ព្រមទាំងសម្ភារការិយាល័យមួយចំនួនបន្ថែមទៀត។

បើតាមការប្រាប់ឱ្យដឹងពី លោក វ៉ាត គីមជាង ប្រធានស្ថានីយ៍ថា "ដំណើរការនៅក្នុងស្ថានីយ៍កសិកម្មបល្ល័ង្គពេលនេះល្អប្រសើរ គឺបានចាប់ផ្ដើមពីចំនុចសូន្យ និងផលិតកម្មមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។" ចាប់តាំងពីពេលចូលរួមអនុវត្តន៍គម្រោងនៅឆ្នាំទី១ មកម្លេះគឺ ឆ្នាំ២០១២ បានសាកល្បងតែ ៣ហិចតា ។ លុះនៅឆ្នាំទី២ ការផលិតបានកើនឡើងដល់ ៦ហិចតា ហើយនៅឆ្នាំទី៣ ទី៤ បានរហូតដល់ ១០ហិចតា។ ផែនការសម្រាប់ឆ្នាំ២០១៦នេះ ស្ថានីយ៍កសិកម្ម បល្ល័ង្គក៏គ្រោងផលិតនៅលើផ្ទៃដី ១០ហិចតានេះដែរ"។ លោក គីមជាង បន្តថា លើផ្ទៃដី ១០ហិចតានេះ ស្ថានីយ៍បានទទួលស្រូវពូជសុទ្ធគ្រឹះ ៣០គីឡូក្រាមក្នុងមួយហិចតាពីគម្រោង។

ផលិតកម្មផលិតស្រូវពូជនៅស្ថានីយ៍គឺ ក្នុងស្រូវពូជសុទ្ធគ្រឹះ ៣០០គីឡូក្រាមលើផ្ទៃដី ១០ហិចតា ផលិតបាន៣២តោន។ ស្រូវពូជដែលផលិតបាន៣២តោន ត្រូវបានលក់ឱ្យក្រុមផលិតពូជស្រូវរបស់គម្រោងចំនួន១០ក្រុម កសិកសមាជិកក្រុមនៅក្នុងខេត្តកំពង់ធំ ព្រមទាំងមានអ្នកទិញមកពីគម្រោងខេត្តកំពង់ចាម ត្បូងឃ្មុំ និងបន្ទាយមានជ័យផងដែរ។ ដើម្បីនិរន្តភាពស្ថានីយ៍បានចាប់ផ្ដើមដំណើរការដោយខ្លួនឯងពីចុងឆ្នាំ២០១៥ ដោយប្រើប្រាស់ថវិការពីការលក់ស្រូវពូជ។ លោក គីមជាងនិយាយថា "មកដល់បច្ចុប្បន្ននេះ មានរយៈពេល៦ខែហើយ គឺមានដំណើរការធម្មតា មិនទាន់ជួបបញ្ហាប្រឈមនៅឡើយ"។ លោក ម៉ាក់ ង៉ែត ទីប្រឹក្សាផ្សព្វផ្សាយកសិកម្មខេត្តកំពង់ធំ បានប្រាប់ឱ្យដឹងថា "ដោយមើលឃើញពីភាពជោគជ័យរបស់ស្ថានីយ៍កសិកម្មបល្ល័ង្គ និងដំណើរការល្អមិនជួបបញ្ហាអ្វី គម្រោងបានដាក់យុទ្ធសាស្ត្រឱ្យប្រតិបត្តិខ្លួនឯង។ គម្រោងនៅតែបន្តពង្រឹងផ្នែកទីផ្សារដល់ស្ថានីយ៍"។

សព្វថ្ងៃនេះស្ថានីយ៍បល្ល័ង្គមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំដោយមានការគាំទ្រពីមន្ទីរកសិកម្មខេត្ត មានក្រុមកសិករផលិតស្រូវពូជ ឃ្លាំងស្តុកស្រូវ និងសម្ភារគ្រប់គ្រាន់សម្រាប់ដំណើរការស្ថានីយ៍បានយ៉ាងល្អ។ លោកប្រធានស្ថានីយ៍កសិកម្មបល្ល័ង្គនិយាយដោយទឹកមុខជឿជាក់ថា "ស្ថានីយ៍នេះនឹងមាននិរន្តភាពដោយសារយើងមានសម្ភារ និងលទ្ធភាពគ្រប់គ្រាន់ក្នុងការផលិតស្រូវពូជលក់ជូនកសិករ"។ លោក គីមជាបានប្តេជ្ញាថានឹងខិតខំប្រឹងប្រែងគ្រប់គ្រងស្ថានីយ៍នេះ ឱ្យមានការរីកលូតលាស់ទៅទៀត។

## ២ កសិករចិញ្ចឹមជ្រូកនៅសណ្ដាន់ទទួលជោគជ័យ



ឃុំសណ្ដាន់៖ លោកស្រី កែ ណឹង មានវ័យ ៥១ ឆ្នាំ ប្ដី អ៊ុន នី អាយុ ៥៧ឆ្នាំ ជាអតីតទាហានកាត់រំសាយដោយសារពិការភាព និងមានកូនស្រី ៣នាក់ក្នុងបន្ទុក។ ក្រុមគ្រួសារបងស្រីរស់នៅភូមិព្រៃគគី ឃុំសណ្ដាន់ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ ក្រុមគ្រួសារបងស្រី កែ ណឹង កាលពីមុនប្រកបរបរបិតស្រាបន្តិចបន្តួច ជួនកាលលក់បង្អែម ព្រមទាំងចិញ្ចឹមជ្រូកមួយពីរតាមលក្ខណៈគ្រួសារ ពោលគឺតាមបែបធម្មតាមិនបានយល់ដឹងពីរបៀបចាក់ថ្នាំបង្ការ និងរបៀបថែទាំឱ្យបានល្អទេ។ ប៉ុន្តែពេលនេះ បងស្រី ណឹង បានទទួលការបណ្ដុះបណ្ដាលពីមន្ត្រីបសុសត្វ ពីរបៀបចិញ្ចឹមជ្រូកឱ្យបានល្អ របៀបដាក់ចំណី របៀបចាក់វ៉ាក់សាំងការពារជាដើម។ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានជ្រើសរើសគ្រួសារបងស្រី ណឹង ជាកសិកបង្ហាញពីការចិញ្ចឹមជ្រូក។ គាត់ទទួលបានមេជ្រូកចំនួន២ក្បាល ដែលមួយក្បាលមានទំងន់ ១៦គីឡូក្រាម លុយ ៥០ដុល្លារសម្រាប់ធ្វើទ្រុង និងចំណីបីបេ។

មុខរបបចិញ្ចឹមជ្រូកមានការលំបាក និងត្រូវការថែទាំដិតដល់ កសិករខ្លះបានជោគជ័យ កសិករខ្លះក៏មិនសូវជោគជ័យដែរ។ ប៉ុន្តែបងស្រី ណឹង វិញគឺមានការជោគជ័យខ្លាំង ជាក់ស្តែងជ្រូកដែលគម្រោងផ្ដល់ឱ្យចំនួន២ក្បាល គឺនៅស្ថិតស្ថេរគង់វង្សបានល្អណាស់ ហើយថែមទាំងផលិតបានកូនជ្រូកច្រើនទៀតផង។ អ្នកស្រី ណឹង បានរៀបរាប់ឱ្យដឹងទាំងញញឹមថា "វគ្គទីមួយ មេជ្រូកទី១ កូនបាន១០ក្បាល និង មេជ្រូកទី២ កូនបាន១៧ក្បាល"។ ក្រោយពីចិញ្ចឹមជ្រូកបានធំធាត់ គាត់ចាប់ផ្ដើមលក់ ៩ក្បាល ដែលមានទំងន់ចន្លោះពី៩,៥ ដល់ ១២,៥ គីឡូក្រាម ក្នុងតម្លៃជាង ៧ លានរៀល ។ នៅវគ្គទី២ មេជ្រូកទី១កើតកូន ១៣ក្បាល និង មេជ្រូកទី២ កើតកូនបាន១៥ក្បាល។ នៅវគ្គទី២នេះ គាត់បានលក់ជ្រូកពេញសាច់ពេញគីឡូចំនួន៩ក្បាល បានថ្លៃ ៨.៨៩៩.០០០ រៀល។

តម្លៃជ្រូកអាចឡើងចុះអាស្រ័យតាមរដូវកាលដែលទីផ្សារមានតម្រូវការខ្លាំងឬតិច។ ប៉ុន្តែទីផ្សារលក់ជ្រូកនៅសណ្តាន់ល្អ ដោយសារមិនសូវមានកសិករចិញ្ចឹមទេ។ អ្នកស្រី ណឹង និយាយដោយញញឹមថា កាលពីគេមិនទាន់ស្គាល់ ខ្ញុំទៅរកអ្នកទិញទូរស័ព្ទទៅឈ្មួញមិនមកផង ប៉ុន្តែពេលចាប់ទៅលក់គេឃើញល្អៗ គេមកសុំទិញដល់កន្លែង។

ចំណូលពីចិញ្ចឹមជ្រូករបស់កសិករមិនត្រឹមតែអាចផ្គត់ផ្គង់គ្រួសារបាន ថែមទាំងនៅសល់សម្រាប់ប្រើប្រាស់ផ្សេងៗ។ បងស្រី ណឹង ក្នុងទឹកមុខរីករាយថា "លុយនៅសល់ខ្ញុំយកធ្វើផ្ទះ ខ្ញុំបានទិញស៊ីម៉ង់ត៍ ទិញអិដ្ឋ ខ្សាច់ និងកំពុងចាក់គ្រឹះសសរគ្រឹះផ្ទះ និងចាប់ផ្តើមធ្វើផ្ទះថ្មី" ។ បងស្រី ណឹង និងប្តី អ៊ិន នី មានភាពសប្បាយរីករាយនឹងលទ្ធផលជ្រូកដែលបានល្អៗ គាត់មានបំណងចង់ពង្រីកបន្ថែមកន្លែងចិញ្ចឹមជ្រូកទៀតនៅពេលធ្វើផ្ទះរួចរាល់៕

## ៣ ចំណូលបន្ថែមពីការចិញ្ចឹមកង្កែបសាច់អាចជួយជីវភាពបានប្រសើរ



បន្ទាយមានជ័យៈ កាលពីមុនកង្កែបត្រូវបានកសិកចិញ្ចឹមធ្វើម្ហូប។ ប៉ុន្តែឥឡូវនេះ កសិករចិញ្ចឹមលក់ ដើម្បីរកចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ កសិករខ្មែរភាគច្រើនចិញ្ចឹម មាន់ ទា បន្ថែមលើការធ្វើស្រែ ចំការគេកម្រចិញ្ចឹមកង្កែបណាស់។ លោក ហូវ ឈាន មានវ័យ ៥២ឆ្នាំ ប្រពន្ធឈ្មោះ ឯ រិទ្ធ អាយុ ៥១ឆ្នាំ និងមានកូន ៥នាក់ ជាកសិករចិញ្ចឹមកង្កែបនៅ ភូមិថ្មី សង្កាត់ភ្នាត ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។

លោក ហូវ ឈាន ចាប់ផ្តើមរបរចិញ្ចឹមកង្កែបបីឆ្នាំហើយ គឺចាប់ពីខែមេសា ឆ្នាំ២០១៣ ដោយបានការណែនាំ និងជ្រើសរើសជាកសិកបង្ហាញពីការចិញ្ចឹមកង្កែប ពីគម្រោងក្រោមកិច្ចសការណ៍ជាមួយ មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ។ មុនពេលចាប់អាជីពចិញ្ចឹមកង្កែប បងប្រុស ឈាន ធ្លាប់ធ្វើជាកម្មករ និងធ្វើស្រែដោយជីវភាពលំបាក។ បច្ចុប្បន្ននេះ គាត់បានចាប់យករបរថ្មីមួយគឺ ការចិញ្ចឹមកង្កែ ដោយប្រើប្រាស់ប៉ាវ៉ាតង់ដែលមានការរីកចំរើនគួរជាទីកត់សម្គាល់។ បងប្រុស ហូវ ឈាន បាននិយាយថា "សព្វថ្ងៃនេះមុខរបររីកចំរើនច្រើន ហើយកង្កែបក៏លក់ដាច់ច្រើនដែរ" ។

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានប្រគល់កូនកង្កែបចំនួន៦០០ក្បាល ដល់កសិករ ហូវ ឈាន សម្រាប់ធ្វើបង្ហាញដល់កសិករផ្សេង។ បងប្រុសបានរៀបរាប់ថា "គម្រោងបានផ្តល់កូនកង្កែបឱ្យចិញ្ចឹម ព្រមទាំងបង្រៀនពីបច្ចេក ទេសចិញ្ចឹម ណែនាំពីរបៀបដាច់ចំណី ថែទាំអនាម័យ និងការព្យាបាល ដូចជាពេលវាហើមពោះជាដើម"។ បងប្រុស ឈាន បានចេញកម្លាំងពលកម្មខ្លួនឯងធ្វើរោង និងជីកសសរ ព្រមទាំងទិញតង់ចំនួន២សម្រាប់ដាក់កង្កែប ។ ការចិញ្ចឹមកង្កែបយកសាច់ ក្នុងអាងប៉ាវ៉ាតង់គឺ ងាយស្រួលធ្វើ និងត្រូវការទីកន្លែងតូច។ បងប្រុស ឈាន និយាយថា "ការធ្វើតង់ចិញ្ចឹមកង្កែបគឺងាយស្រួលទេ"។

ការចិញ្ចឹមកង្កែបជាមុខរបរដែលអាចជួយដល់ជីវភាពប្រសើរ។ វាចំណាយពេលចិញ្ចឹមតែ២ខែ ៥០ថ្ងៃ អាចចាប់លក់បាន។ កង្កែបចំនួន៥ មានទំងន់១គីឡូ ហើយក្នុងមួយគីឡូ លក់បានប្រាក់ជាមធ្យម ៨០០០រៀល។

ដោយតម្រូវការកង្កែបនៅតាមទីផ្សារកាន់តែច្រើនឡើងៗ បងប្រុសឈាន បានពង្រីកកន្លែងចិញ្ចឹមកង្កែបពី២ប៉ាវ៉ាតង់ ដល់១០ប៉ាវ៉ាតង់។ លោក ហូវ ឈាន បាននិយាយថា "ក្នុងមួយតង់ៗអាចដាក់កង្កែបបាន១២០០ក្បាល ហើយក្នុងមួយតង់ចិញ្ចឹមកង្កែប ចំណាយអស់ប្រាក់៩ម៉ឺនរៀល។ ពេលលក់មួយតង់មានកង្កែប២០០គីឡូក្រាម លក់បានប្រាក់ ១លាន ៦ម៉ឺន"។ កម្រិតជីវភាពរបស់កសិករចិញ្ចឹមកង្កែប ហូវ ឈាន បានភាពប្រសើរជាងមុន។ គាត់មានការត្រេកអរយ៉ាងខ្លាំងដោយមុខរបររបស់គាត់ទទួលបានជោគជ័យ។ លោក ហូវ ឈាន បានថ្លែងអំណរគុណគម្រោងដែលបានជួយជីវភាពគ្រួសារគាត់បានធូរធាជាងមុន។



# ៤ ការអភិវឌ្ឍកសិកម្មខ្នាតតូចជួយកែលម្អជីវភាពគ្រួសារ



សៀមរាប៖ កសិករ ណយ នាត ភេទស្រី វ័យ ៤៥ឆ្នាំ ត្រូវបានអ្នកភូមិទទួលស្គាល់ថា ជាកសិករគំរូម្នាក់នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប។ គ្រួសារអ្នកស្រី ណួយ នាត ត្រូវបានគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជ្រើសរើសឱ្យធ្វើជាកសិករចូលរួមចិញ្ចឹមសត្វបង្ហាញគឺ ចិញ្ចឹមជ្រូកសាច់ក្នុងសង្កាត់គោលដៅគម្រោង ឆ្នាំ២០១៤។ មុនពេលចូលគម្រោងក្នុងឆ្នាំ២០១៣ គាត់ និងប្តីរបស់គាត់ លោក ឆាង ប្រាច់ អាយុ៥០ឆ្នាំ ជាកម្មករសំណង់ មានកូនស្រី៤នាក់ក្នុងបន្ទុក។ បងស្រីរស់នៅក្នុងជីវភាពខ្វះខាតខ្លាំង ដោយពឹងលើការងារកសិកម្មរួមផ្សំលើផ្ទៃដីតូច២.០០០ម៉ែត្រការ៉េ និងការលក់កម្លាំងពលកម្មប្រចាំថ្ងៃ។

ដោយមើលឃើញភាពព្យាយាម និងការប្តេជ្ញាចិត្តខ្ពស់របស់បងស្រី ណយ នាត គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតនៅតូចតំបន់ទន្លេសាប បានគាំទ្រជាបច្ចេកទេសចិញ្ចឹមពូជសត្វ សម្ភារសាងសង់ទ្រុង ចំណីផ្សំ ការចាក់វ៉ាក់សាំង ព្រមទាំងការប្រឹក្សាបច្ចេកទេស យ៉ាងជាប់លាប់។ ក្នុងរយៈពេល ២ឆ្នាំ នៃការចិញ្ចឹមសត្វដោយប្រើប្រាស់ធនធានដែលរកបានជាចំណីរួមផ្សំ ជ្រូករបស់គាត់បានលក់រហូតដល់១៦ក្បាល។ បច្ចុប្បន្ននេះ គាត់នៅសល់មេជ្រូកពីរក្បាល កំពុងចិញ្ចឹមបន្តសំរាប់លក់កូនជ្រូក។ តាមការវិភាគសេដ្ឋកិច្ច គាត់ទទួលបានប្រាក់ចំណេញប្រហែល ៨លានរៀលដែរក្នុងមួយវគ្គៗ។ ដោយមានការរីកចំរើនគួរសម អ្នកស្រី ណួយ នាតបានយកប្រាក់ដែលចំណេញពីការចិញ្ចឹមជ្រូក មកធ្វើចំការដំណាំសម្រាប់បង្កើតមុខរបរកសិកម្មបន្ថែមដូចជា ដាំដំណាំត្រសក់ផ្អែម ក្នុងផ្ទៃដី ៥០០ម៉ែត្រការ៉េ ត្រសក់ស្រូវក្នុងផ្ទៃដី ២០០ម៉ែត្រការ៉េ និងម្ទេសហាវ៉ៃក្នុងផ្ទៃដី ២០០ម៉ែត្រការ៉េផងដែរ។

បងស្រី ណួយ នាត បានប្រាប់អោយដឹងថា មុខរបរនេះខ្ញុំបង្កើតហើយត្រូវតែតស៊ូ ដោយសារតែវាអាចជួយដោះស្រាយជីវភាពគ្រួសារបាន។ ដោយមានការរីកចម្រើនក្នុងរបរចិញ្ចឹមជ្រូក និងដំណាំប្តីរបស់គាត់បានឈប់ពីការងារ សំណង់ហើយមកជួយការងារបង្កបង្កើនផលកសិកម្មប្រពន្ធវិញ។

លោកស្រី មុយ សុភេន ប្រធានក្រុមគាំទ្របច្ចេកទេសកសិកម្មក្រុងសៀមរាប មានចំណាប់អារម្មណ៍ថា ការជ្រើសរើសបងស្រី ណួយ នាត មកធ្វើជាកសិករបង្ហាញបានលទ្ធផលល្អប្រសើរ ជាពិសេសគាត់មានគំនិតពង្រីកមុខរបរបន្ថែមទៀត។ លោកស្រី សុភេន បន្តថា គាត់មិនខ្លាចដូចមុនទេ ឥឡូវគាត់អាចធ្វើការធ្វើបង្ហាញនេះល្អ គាត់មានការរីកចំរើនច្រើនជាងមុន កាលមុនបងស្រី ណួយ នាត ពិបាកក្នុងការប្រាស្រ័យទាក់ទងជាមួយគេមកពីខាងក្រៅ ប៉ុន្តែពេលនេះគាត់អាចធ្វើការបង្ហាញពីសមិត្ថិផលរបស់គាត់។ ជាក់ស្តែពេលថ្មីៗនេះ មានអ្នកទស្សនៈកិច្ចពីខេត្តត្បូងឃ្មុំ និងកំពង់ចាម និងមន្ត្រីថ្នាក់ដឹកនាំចុះមកមើលពីភាពជោគជ័យរបស់គាត់។ ពេលនេះ គាត់មានបងពិសោធន៍ច្រើន និងមានចំណូលកាន់តែច្រើនអាចផ្គត់ផ្គង់ជីវភាពគ្រួសារបាន។



គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានជួយឱ្យគាត់ទទួលបាននូវចំណេះដឹងថ្មីៗ និងបទពិសោធន៍ល្អៗ ក្នុងការគ្រប់គ្រងសត្វរបស់គាត់យ៉ាងមានប្រសិទ្ធភាជាមួយនឹងប្រាក់ចំណូលគ្រឹះ ដែលអាចជួយឲ្យគ្រួសារគាត់អាចពង្រីកមុខរបរកសិកម្ម និងបង្កើនប្រាក់ចំណូលសំរាប់លើកស្ទួយជីវភាពក្រុមគ្រួសារ។ បងស្រី ណឹង ក៏មានឆន្ទៈចែករំលែកបច្ចេកទេស និងបទពិសោធន៍ដល់កសិករផ្សេងទៀត ដែលមានចំណាប់អារម្មណ៍ដូចគាត់ ទាំងការចិញ្ចឹមជ្រូក និងការដាំដុះដំណាំដើម្បីឱ្យមានការរីកចម្រើនទាំងអស់គ្នា។